# កិច្ចការបញ្ចប់មេរៀនទី១៩-តួអង្គ

**អំណាន:** ចូរអានរឿងខាងក្រោម រួចឆ្លើយនឹងសំណួរ ។

## រឿងទឹកចិត្តមេមាន់

កសិករម្នាក់បានចិញ្ចឹមមាមាន់មួយ និងមេទាមួយ ។

មេមាន់ភ្ញាស់បានកូនមួយសម្បុក ។ មេទាក៏ភ្ញាស់បានកូនមួយសម្បុកដែរ ហើយក៏ចាកចោលកូនទៅ ។ មេមាន់ឃើញកូនទាកំព្រា ក៏យកមកចិញ្ចឹម ។ កូនមាន់ឆ្ងល់ក៏សួរ ៖ " ម៉ែ! ហេតុអ្វីបានជាម៉ែចិញ្ចឹមកូនទា ? " ។ មេមាន់ឆ្លើយ ៖ " កូនទាកំព្រា វាត្រូវការថែទាំដូចកូនដែរ " ។ ម៉ែចិញ្ចឹមវា ព្រោះតែវាក៏មានសិទ្ធិរស់រានមានជីវិតដូចកូនដែរ ។ កូនមាន់សួរ ៖ " ម៉ែគិត ចិញ្ចឹមកូនទារហូតឬ? " ។ មេមាន់ឆ្លើយ ៖ " ទេ! ដល់វាគ្រប់អាយុម៉ែឱ្យវារៀនជាមួយកូនហើយដល់វាអាចចិញ្ចឹមខ្លួនបានម៉ែឈប់ជួយវាហើយ " ។ កូនៗលាន់មាត់ ៖ " យី! ម៉ែខ្ញុំចិត្តល្អណាស់ " ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើកសិករនោះចិញ្ចឹមសត្វអ្វី ?

☐ក. គោ ក្របី ☐ខ. មេមាន់មួយ និងមេទាមួយ

☐គ. ទា និងសេះ ☐ឃ. មាន់ និងជ្រូក

២. ហេតុអ្វីបានជាកូនទាមករស់នៅជាមួយមេមាន់ ?

☐ក. មេរបស់វាចាកចោល ☐ខ. មេរបស់វាមានជំងឺធ្ងន់ធ្ងរ

☐គ. មេរបស់វាងាប់ ☐ឃ. មាន់ និងជ្រូក

៣. ហេតុអ្វីបានជាមេមាន់ចិញ្ចឹមកូនទា ?

☐ក. ព្រោះមេមាន់គ្មានកូន ☐ខ. ចង់ឱ្យកូនទាបម្រើខ្លួន

☐គ. ព្រោះកូនទាកំព្រាត្រូវការការថែទាំ ☐ឃ. ចង់ឱ្យកូនរបស់ខ្លួនមានគ្នាលេងជាមួយ

៤. តើរឿងនេះមានតួអង្គអ្វីខ្លះ ?

☐ក. កសិករ មេមាន់ មេទា កូនមាន់ កូនទា ☐ខ. កសិករ មេមាន់ មេទា គោ ក្របី

☐គ. កសិករ មេមាន់ មេទា ឆ្មា ឆ្កែ ទន្សាយ ☐ឃ. កសិករ មេមាន់ មេទា ជ្រូក ឆ្កែ ឆ្មា

៥. តើមេមាន់ជាតួអង្គដូចម្តេច ?

☐ក. គិតតែផលប្រយោជន៍របស់ខ្លួន ☐ខ. ចិត្តអាក្រក់

☐គ. លោភលន់ ចូលចិត្តធ្វើបាបអ្នកដទៃ ☐ឃ. ចិត្តល្អ ចេះជួយសង្គ្រោះអ្នកដទៃ

LIVEWORKSHEETS

➢ សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម " កំព្រា សិទ្ធិ " ។

- កំព្រា ( ) ........................................................................................................... ។

- សិទ្ធិ ( )............................................................................................................. ។

២. ដូចម្តេចដែលហៅថាតួអង្គ ។

○ ......................................................................................................................។

## រឿងអណ្តាត និងបេះដូង

ថ្ងៃមួយបុរសម្នាក់បង្គាប់ទៅអ្នកបម្រើយកជ្រូកនៅក្នុងទ្រុងយកទៅសម្លាប់ ។ បុរសនោះប្រាប់អ្នកបម្រើឱ្យយកអ្វីដែលល្អជាងគេនៅក្នុងខ្លួនជ្រូកនេះឱ្យទៅគាត់ ។ អ្នកបម្រើធ្វើតាមបញ្ជា ហើយក៏យកបេះដូង និងអណ្តាតទៅជូនចៅហ្វាយ ។ បួនប្រាំថ្ងៃក្រោយមក ចៅហ្វាយក៏បង្គាប់អ្នកបម្រើឱ្យចាប់ជ្រូកមួយទៀតទៅសម្លាប់ ហើយឱ្យយកអ្វីដែលអាក្រក់បំផុតក្នុងខ្លួនជ្រូកមកឱ្យគាត់ ។ អ្នកបម្រើនោះក៏យកបេះដូង និងអណ្តាតមកជូនចៅហ្វាយដូចមុនទៀត ។ ចៅហ្វាយក៏សួរ ៖ " ហេតុដូចម្តេច បានជាឯងនៅតែយកបេះដូង និងអណ្តាតមកដដែលៗដូច្នេះ ? " ។

បាវក៏ឆ្លើយថា សូមលោកជ្រាប " ល្អ ឬអាក្រក់ " មកតែពីសម្តី និងចិត្តនេះឯង គឺអណ្តាត និងបេះដូង ។

៣. ចូរស្រង់តួអង្គនៅក្នុងរឿងអណ្តាត និងបេះដូង ខាងលើ ។

..........................................................................................................................។

៤. តើរឿងអណ្តាត និងបេះដូង លោកចៅហ្វាយឱ្យអ្នកបម្រើសម្លាប់ជ្រូកយកអ្វីមកជូនគាត់ ?

..........................................................................................................................។

៥. ហេតុអ្វីបានជាអ្នកបម្រើយកបេះដូង និងអណ្តាត ជូនចៅហ្វាយដដែល ៗ ?

..........................................................................................................................។

LIVEWORKSHEETS